-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ ._** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទាន ថវិកា ចំនួន ៥០០ លានរៀល (ប្រាំរយលានរៀល) ពីជំពូក ៣០ (អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច) មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាលសំភារៈ និងជួសជុលបច្ចេក) របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨ ។

**មាត្រា ២ ._** ឥណទានថវិកាក្នុងមាត្រា១ ខាងលើត្រូវបានអនុញ្ញាតអោយប្រើប្រាស់សំរាប់បំពេញតំរូវការចំណាយប្រេងឥន្ធនៈដែលខ្វះក្នុង ឆមាសទី២ ឆ្នាំ ១៩៩៨ ។

**មាត្រា ៣ ._** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

**អ៊ឹង ហួត** **ហ៊ុន សែន**

★ ★ ★

## អនុក្រឹត្យលេខ ៦៣ អនក្រ.បក

## ស្តីពីការរៀបចំ ទិវាទេសចរណ៍ពិភពលោក

***

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និង ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៥៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-យោងសេចក្តីណែនាំរបស់អង្គការទេសចរណ៍ពិភពលោក ( WTO )

-យោងសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

**សំរេច**

មាត្រា ១ ._ កំណត់យកថ្ងៃទី ២៧ ខែ កញ្ញា ជារៀងរាល់ឆ្នាំសំរាប់រៀបចំប្រារព្ធទិវាទេសចរណ៍ ពិភពលោកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២ ._ បង្កើតគណៈកម្មការជាតិមួយសំរាប់រៀបចំប្រារព្ធទិវាទេសចរណ៍ពិភពលោកនៅថ្ងៃទី ២៧ ខែ កញ្ញា ដែលមានសមាសភាពដូចខាងក្រោម ៖ .

| | |
|---|---|
| ១-តំណាង ក្រសួងទេសចរណ៍ | ជាប្រធាន |
| ២-តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី | ជាអនុប្រធាន |
| ៣-តំណាង ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ជាអនុប្រធាន |
| ៤-តំណាង ក្រសួងមហាផ្ទៃ | សមាជិក |
| ៥-តំណាង ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៦-តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧-តំណាង ក្រសួងពត៌មាន | សមាជិក |
| ៨-តំណាង ក្រសួងបរិស្ថាន | សមាជិក |
| ៩-តំណាង រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១០-តំណាង ក្រុមហ៊ុនអាកាសចរភូមិន្ទកម្ពុជា | សមាជិក |
| ១១-តំណាង អាជ្ញាធរខេត្ត- ក្រុង | សមាជិក |

មាត្រា ៣ ._ គណៈកម្មការជាតិនេះមានភារកិច្ចរៀបចំប្រារព្ធទិវាទេសចរណ៍ពិភពលោករៀងរាល់ ឆ្នាំ ចាប់ពីឆ្នាំ ១៩៩៩នេះតទៅ ។ ការរៀបចំទិវានេះ គឺក្នុងគោលបំណងបង្ហាញការយកចិត្តទុកដាក់ចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងសហគមន៍អន្តរជាតិ ព្រមទាំងបង្ហាញពីឬទ្ធានុភាពជាតិលើឆាកអន្តរជាតិ។ លើកកំពស់ការយល់ដឹងអំពីអត្ថប្រយោជន៍ នៃវិស័យទេសចរណ៍ក្នុងការចូលរួមចំណែកស្តារ និងកសាងសង្គម និង សេដ្ឋកិច្ចជាតិនៅក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។

មាត្រា ៤ ._ គណៈកម្មការជាតិនេះ មានសិទ្ធិប្រើត្រាសំរាប់របស់ក្រសួងទេសចរណ៍ ។

មាត្រា ៥ ._ គណៈកម្មការជាតិនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការមួយចំនួនបើមានការចាំបាច់ ។

មាត្រា ៦ ._ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវសំរួលផ្តល់ថវិកាជូនគណៈកម្មការនេះ តាមការជាក់ស្តែង ។

មាត្រា ៧ ._ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលគ្រប់ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ឹង ហួត ហ៊ុន សែន